ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល
លេខ : ៤១៤សហវ

ភ្នំពេញ ថ្ងៃទី០១ ខែ កក្កដា ឆ្នាំ២០០២

# ប្រកាស
## របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## និងក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល
## ស្តីពី
## ការរំលាយចោលកិច្ចសន្យាជួលរោងចក្រយន្តសាស្ត្រទី៦

❋❋❋❋❋❋❋❋❋❋

១-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

២-បានឃើញព្រះរាជក្រឹត្យលេខ នស/រ.ក.ត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

៣-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩

៤-បានឃើញអនុក្រឹត្យលេខ០៤/អនក្រ/បក ចុះថ្ងៃទី២០ ខែមករាឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៥-បានឃើញអនុក្រឹត្យលេខ៣៥ /អនក្រ/បកចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល

៦-យោងកិច្ចសន្យាជួលរោងចក្រយន្តសាស្ត្រទី៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៤

៧-យោងលិខិតលេខ ១.៨៧៥ សហវ.ទរ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច :**

**ប្រការ១ :** រំលាយចោលកិច្ចសន្យាជួលរោងចក្រយន្តសាស្ត្រទី៦ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៤ និងដកហូតទីតាំងរោងចក្រយន្តសាស្ត្រទី៦ដែលស្ថិតនៅតាមដងផ្លូវជាតិលេខ ៥ "គីឡូម៉ែត្រលេខ៦" ពីលោក EWE SWEE KHENG តំណាងក្រុមហ៊ុន CAMBODIA WINERY PRIVATE LTD ដោយមូលហេតុមិនគោរពតាមកិច្ចសន្យា ។

**ប្រការ២** : លោក EWE SWEE KHENG ត្រូវទូទាត់បំណុលថ្លៃឈ្នួលទីតាំងរោងចក្រយន្តសាស្ត្រទី៦ ត្រឹមត្រីមាសទី១ ឆ្នាំ២០០២ ដែលមានទឹកប្រាក់សរុបចំនួន ២៣៥.០០០$ (ពីររយសាមសិបប្រាំពាន់) ដុល្លារអាមេរិក និងប្រាក់ពិន័យចំនួន ៥៣៤.១៣០$ (ប្រាំរយសាមសិបបួនពាន់មួយរយសាមសិប) ដុល្លារអាមេរិកជូនរដ្ឋក្នុងរយៈពេល៣០ថ្ងៃជាកំហិត គិតចាប់ពីថ្ងៃដែលបានចេញប្រកាសរំលាយចោលកិច្ចសន្យា និងដកហូតទីតាំងរោងចក្រយន្តសាស្ត្រទី៦ជាផ្លូវការ ។

**ប្រការ៣** : កិច្ចសន្យាជួលរោងចក្រយន្តសាស្ត្រទី៦ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៤ និងលិខិតបទដ្ឋានដទៃទៀតដែលមានការពាក់ព័ន្ធនឹងការជួលនិងប្រគល់ទីតាំងរោងចក្រយន្តសាស្ត្រទី៦ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** : នាយកដ្ឋាន ទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុនៃក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល និងលោក EWE SWEE KHENG មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

**ប្រការ៥** : ប្រកាសអន្តរក្រសួងនេះមានប្រសិទ្ធិភាពអនុវត្តជាគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ២០០២

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** | **ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល** |
| **គាត ឈន់** | |

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិនៃកម្ពុជា នាយកដ្ឋានប្រតិបត្តិការ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាក្រុងភ្នំពេញ
- សាលាខ័ណ្ឌឫស្សីកែវ
- ដូចប្រការ ៤ ដើម្បីអនុវត្ត
- ឯកសារ